**Program:** Crime Before Bed

**Topic**: **Natalee Holloway** (ការបាត់ខ្លួនយ៉ាងអាថ៌កំបាំងរបស់ **Natalee Holloway**)

**Categories:** Crime Investigation

**Publish Date:** Wednesday 1st, September 2021

**Content by:** Prey Reung



----------------------------------------------------------------------------

**Hook**

សូមស្វាគមន៍មកកាន់ CamID Podcast!

នារីម្នាក់ដែលជាសិស្សពូកែប្រចាំសាលា ហើយក៏ជាសិស្សដែលនឹងទទួលបានអាហារូបករ៍ ១០០%

ផងដែរ តែអ្វីៗគឺប្រែទៅជាសូន្យទាំងអស់ ក៏ដោយសារតែ នាងបានបាត់ខ្លួនយ៉ាងអាថ៌កំបាំង

ក្នុងយប់ដែលនាងបានធ្វើដំណើរកំសាន្តលើកោះមួយ។

ចង់ដឹងថារឿងរ៉ាវនេះ កើតឡើងយ៉ាងដូចម្តេច យើងទៅតាមដានទាំងអស់គ្នា។

**Intro**

នៅលើពិភពលោកយើងមានហេតុការណ៍ចំលែកៗ

និងអាថ៌កំបាំងជាច្រើនដែលមិនមានអ្នកណាអាចបកស្រាយបាន

ហើយជាពិសេសហេតុការណ៏ដែលធ្វើអោយមនុស្សលោកយើងព្រួយបារម្ភណ៍គឺ

ការដែលបាត់ខ្លួនមិនឃើញត្រលប់មកវិញសម្បីតែពាក្យសារចុងក្រោយ សាកសព

ឬក៏តម្រុយផ្សេងៗដែលសាច់ញាតិ និងប៉ូលិសក្រុមអ្នកស៊ើបអង្កេត មិនអាចតាមរកបានមកវិញ។

អ្នកខ្លះបាត់ខ្លួនហើយក៏ត្រឡប់មកវិញជួបជុំគ្រួសារវិញដោយសុវត្ថិភាព អ្នកខ្លះត្រូវគេចាប់ជំរិត ខ្លះត្រូវគេសម្លាប់ និងមានមូលហេតុផ្សេងៗជាច្រើនទៀត ដែលធ្វើអោយពួកគេបាត់ខ្លួន។

ប៉ុន្តែថ្ងៃនេះព្រៃរឿងនឹងលើកយករឿងរ៉ាវបាត់ខ្លួនរបស់នារីម្នាក់អស់រយៈពេល១៦ឆ្នាំ ដោយមិនដឹងមូលហេតុ។

មានសំណួរជាច្រើនជុំវិញរឿងនេះថាតើនាងត្រូវគេសម្លាប់ឬក៏យ៉ាងណា? ហើយអ្នកណាជាអ្នកទទួលខុសត្រូវលើរឿងនេះ?

**Body**

រឿងរ៉ាវនេះផ្តើមចេញពីនារីម្នាក់ដែលមានឈ្មោះថា Natalee Holloway។ នាងកើតនៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៨៦ នៅរដ្ឋMississippi និងធំដឹងក្តីនៅក្រុងMountain Brook ដែលស្ថិតនៅជាយដែនរដ្ឋ Alabama។ គ្រួសាររបស់នាងធូធា ហើយនាងមានប្អូនប្រុសម្នាក់ឈ្មោះ Matt Holloway។ ឪពុករបស់នាងឈ្មោះ Dave Holloway រីឯម្តាយរបស់នាងឈ្មោះBeth Holloway។

ប្តីប្រពន្ធគេទាំងពីរបានបែកបាក់គ្នាតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ។ Natalee រស់នៅជាម្តាយរបស់គេតាំងពីពេលហ្នឹងមក រហូតដល់នាងរៀនចប់មហាវិទ្យាល័យ Mountain Brook។

នាងត្រូវបានមិត្តភក្តិ និងគ្រូបង្រៀនរបស់នាងស្ញើចសរសើរ ព្រោះនាងជាសិស្សម្នាក់ដែលលេចធ្លោជាងនៅក្នុងថ្នាក់ និងចេះជួយយកអាសារមនុស្សជុំវិញខ្លួននាង

ហើយថែមទាំងរៀនពូកែ និងចេះរាំទៀតផង។ ក្រៅពីការសិក្សានាងក៏ចូលចិត្តរាំ និងធ្វើការងារស្ម័គ្រនៅក្នុងសាលាផងដែរ។

នៅខែឧសភា ឆ្នាំ២០០៥ ថ្ងៃដែលនាងរង់ចាំក៏បានមកដល់។ ការតស៊ូ និងការប្រឹងប្រែងរៀនសូត្ររបស់ Natalee កន្លងមកបានជួយអោយនាងបញ្ចប់ថ្នាក់មហាវិទ្យាដោយជោគជ័យ។

មិនត្រឹមតែប៉ុណ្ណោះ នាងក៏ត្រូវបានសកលវិទ្យាល័យ Alabama ផ្តល់អាហាររូបករណ៍១០០% ដើម្បីបន្តការសិក្សាផ្នែករោគកុមារថែមទៀតផង។ ជាមួយគ្នាហ្នឹងដែរ សាលាក៏មានដំណើរកម្សាន្តរយះពេល៥ថ្ងៃជុំគ្នានៅឯកោះ Aruba នៃប្រទេស ហូឡង់ ផងដែរ។

តែអ្នកណាទៅដឹងថា សុបិន្តអាក្រក់របស់នាង និងក្រុមគ្រួសារនាងក៏បានមកដល់បន្ទាប់ពីនាងទៅដល់កោះនោះ!

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៥ Natalee និងសិស្សផ្សេងៗចំនួន ១២៤នាក់ទៀត ដែលទើបតែចប់ថ្នាក់មហាវិទ្យាល័យ បានទៅដល់កោះAruba។

ព្រៃរឿងសូមបញ្ជាក់ផងដេរថា ដោយចំនួនអ្នកទៅច្រើនពេកទើបធ្វើអោយពួកគេទាំងអស់ដើរកំសាន្តដោយខ្លួនឯងតាមដែលចិត្តចង់ ហើយមានអ្នកមើលការខុសត្រូវដែលមានវ័យជំទង់ទៅជាមួយតែ៧នាក់ប៉ុណ្ណោះ។

ថ្ងៃដំបូង ពួកគេទាំងអស់បានទៅដើរកំសាន្តនៅឯរមណីដ្ឋាន Holiday Inn ដែលមានទីតាំងនៅក្បែរមាត់សមុទ្រ។

រំលងបាន២ថ្ងៃ ពោលគឺនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ Natalee និងមិត្តភក្តិរបស់គេប៉ុន្មានដល់នាក់ទៀតបានទៅសណ្ឋាគារកាស៊ីណូមួយនៅក្បែរនោះ។ ពួកគេបានជួបបុរសវ័យជំទង់សញ្ជាតិហូឡង់ម្នាក់អាយុ ១៧ឆ្នាំម្នាក់ ឈ្មោះថា Joran Vander Sloot ដែលរស់នៅក្បែរនោះ។

គ្រានោះJoranបាននិយាយជាមួយNatalee និងមិត្តភក្តិរបស់នាង។ បន្ទាប់មកពួកគេទាំងប៉ុន្មាននាក់រួមទាំង Joran បានទៅរួមដំណើរគ្នាទៅលេងកន្លែងផឹកស៊ីមួយកន្លែងឈ្មោះថា Carlos 'n Charlie's Bar។ ពួកគេបានផឹកស៊ី និងរាំសប្បាយជុំគ្នា។ រីឯ Natalee គ្រានោះក៏ស្រវឹងជោគជាំផងដែរ។

ដល់វេលាម៉ោង១យប់កណ្តាលអាធ្រាត ឈានចូលថ្ងៃទី៣០ Natalee ត្រូវបានមិត្តភក្តិរបស់នាងប្រទះឃើញជិះឡានជាមួយ Joran និងមិត្តរបស់គេពីរអ្នកទៀតគឺ Deepak និងSatish Kalpoe។

មិត្តរបស់នាងមិនបានសង្ស័យអ្វីទេ

និងគិតថាល្អហើយដែលមានគេជូនទៅNataleeទៅសណ្ឋាគាររបស់នាងវិញ ។ប៉ុន្តែអ្វីគ្រប់យ៉ាងផ្ទុយការគិតរបស់របស់ពួកគេ ។

លុះព្រឹកឡើង មិត្តរប់ស់នាងទាំងប៉ុន្មានមិនបានឃើញវត្តមានរបស់

Nataleeត្រៀមខ្លួនធ្វើដំណើរត្រឡប់ទៅផ្ទះវិញទេ ហើយពួកគេក៏មិនដឹងថានាងនៅទីណាដែរ ។

ចំណែកឯ Passport និងកាតាបរបស់នាងនៅក្នុងបន្ទប់សណ្ឋាគារដែលនាងស្នាក់នៅដដែរ

ហើយក៏គ្មាននរណាប៉ះពាល់របស់របររបស់នាងនោះទេ ។ មិនយូរប៉ន្មាន

អ្នកមើលការខុសត្រូវរបស់នាងបានពាំនាំដំណឹងនេះទៅកាន់ម្តាយរបស់នាងគឺ Beth ។

ដោយមានចិត្តតក់ក្រហល និងចង់អោយកូនស្រីគាត់ត្រឡប់មកផ្ទះវិញ Bethមិនរង់ចាំយូរនោះឡើយ ។

នៅយប់ថ្ងៃដដែរ Beth និងមិត្តភក្តិក្រុមគ្រួសាររបស់គាត់ ក៏បានទៅដល់កោះAruba ។

បន្ទាប់ពីការបាត់ខ្លួនរបស់Natalee បានមួយថ្ងៃ ។ទីបំផុតប៉ូលិសក៏បារប្រកាសការបាត់ខ្លួនជាផ្លូវការរបស់

Natalee ហើយក្រុមប៉ូលិស Aruban និងសហរដ្ឋអាមេរិកបានសហការន៏គ្នាជាមួយ នឹងគ្រួសាររបស់

Natalee ក្នុងការស្វែងរកNatalee ។

គ្រានោះមានអ្នកស្ម័គ្រចិត្តរាប់រយអ្នកមកពីរដ្ឋTexasនៃសហរដ្ឋអាមេរិក និងអ្នកទេសចរណ៏នៅ Aruban

ផងដែរ បូករួមជាមួយក្រប៉ាល់ជ្រមុជទឹកហូឡង់ជាច្រើនគ្រឿង

ហើយយន្តហោះសង្គ្រោះបន្ទាន់៣គ្រឿងរបស់សហរដ្ឋអាមេរិក បានស្វែងរកNataleeជុំវិញកោះនោះ

មានទាំងក្នុងទឹក លើគោកគ្រប់ទីកន្លែងទាំងអស់

ប៉ុន្តែគ្មាននណារកឃើញសញ្ញាណាមួយបញ្ជាក់ថានាងនៅរស់ ឬក៏ស្លាប់នោះទេ។

បើនិយាយពីគ្រួសាររបស់ Natalee វិញ

ពួកគេបានធ្វើការចោទសួរជុំវិញអ្នកដែលពាក់ព័ន្ធជាមួយកូនស្រីគាត់ផងដែរ រួមមាន មិត្តភក្តិរបស់នាង

ម្ចាស់រមណីដ្ឋាន Holiday Inn និងជាពិសេសJoran ដែលនៅជាមួយកូនស្រីរបស់គាត់នៅយប់នោះ។

អ្នកទាំងអស់គ្នាប្រាកដជាឆ្ងល់ហើយថា តើJoran ជាអ្នកដែលធ្វើអោយកូនស្រីរបស់គាត់បាត់ខ្លួន

ឬក៏យ៉ាងណា?

បើយើងងាកមកស្តាប់ចម្លើយរបស់ Joranវិញ Joranបានឆ្លើយថា

នៅយប់នោះគេបានដឹកនាងចេញពីកន្លែងផឹកស៊ីនោះ ហើយជូននាងទៅផ្ទះភ្លើងហ្វាមួយ

ឯនៅមាត់សមុទ្រដែលភាសាអង់គ្លេសហៅថា LightHouse ព្រោះ Natalee ចង់ទៅមើលត្រីឆ្លាម

រួចរូបគេក៏ជូននាងទៅកាន់ Holiday Inn វិញម៉ោង២យប់ ដោយNatalee

ស្ថិតក្នុងស្ថានភាពស្រវឹងនៅឡើយ។

Joranក៏បានបញ្ជាក់ដែរថា ចម្លើយរបស់គេគឺជាការពិត។ ទោះជាយ៉ាងណាក៏ដោយក៏ Joran និងមិត្តរបស់ពីរនាក់ទៀតក្លាយជាជនសង្ស័យសំខាន់ដែរ។

ប៉ូលិសបានចាប់ខ្លួនអតីតសន្តិសុខអូតែលយកមកឃុំឃាំង និងសួរចម្លើយ ក៏ប៉ុន្តែត្រូវបានដោះលែងវិញបន្ទាប់ពី៨ថ្ងៃក្រោយមក។

រួចប៉ូលិសក៏ការបានធ្វើការចាប់ខ្លួនឪពុករបស់ Joranដែរ គឺ Paulus ក៏ប៉ុន្តែឪពុករបស់គេមិនបានជាប់ពាក់ព័ន្ធជាមួយកូនរបស់គាត់នោះទេ រួចក៏ត្រូវដោះលែងដូចគ្នា។

សរុបទាំងអស់ប៉ូលិសបានចាប់ខ្លួនមនុស្ស ១០នាក់ផ្សេងៗគ្នា យ៉ាងណាពួកអ្នកទាំងនោះមិនបានទទួលបន្ទុក ពីការបាត់ខ្លួនរបស់ Natalee នោះទេ។

ក្រោយមកគេបានរកឃើញកុម្ពសក់មួយ ដែលជាប់នឹងស្កុតក្បែរមាត់ច្រាំងសមុទ្រ Aruba។

ការរកឃើញនេះគឺជាក្តីសង្ឃឹមមួយរបស់ក្រុមគ្រួសារ Natalee តែជាអកុសល លទ្ធផលធ្វើតេស្តសក់នោះបានបង្ហាញថាវាមិនមែនជាសក់របស់ Natalee ទេបន្ទាប់ពី FBI យកទៅពិនិត្យរួច។

មកដល់ចំណុចនេះ ព្រៃរឿងសូមនិយាយពី Joran និងមិត្តរបស់គេវិញម្តង ព្រោះពួកគេជាជនសង្ស័យសំខាន់ដែលនិយាយថាឃើញNataleeចុងក្រោយនៅឯសណ្ឋាគារ Holiday Inn នៅយប់នោះ។ រឿងរ៉ាវក៏បានផ្លាស់ប្តូរនៅពេលដែលពួកគេទាំងបីត្រូវបានប៉ូលិសចាប់ឃុំឃាំងនៅថ្ងៃទី៩ខែមិថុនាឆ្នាំ២០០៥ ហើយ Kalpoe ដែលជាមិត្តរបស់ Joran បាននិយាយថារូបគេបានទម្លាក់មិត្តរបស់គេនិង Natalee នៅឯឆ្នេងសមុទ្រ រីឯ Joran ជាអ្នកទុកនាងនៅឯទីនោះម្នាក់ឯង។

មួយខែក្រោយមក តុលាការសម្រេចដោះលែង Kalpoe ហើយបន្តឃុំខ្លួន Joran និង Deepak រយះពេល៦០ថ្ងៃថែមទៀត។

សរុបមកពួកគេទាំងបីអ្នកត្រូវគេចាប់ខ្លួនបីលើក គឺ២លើក្នុងឆ្នាំ២០០៥ និងមួយលើកទៀតឆ្នាំ ២០០៧ ហើយ ពួកគេទាំងបី ត្រូវបានគេដោះលែងអោយមានសេរីភាពដោយគ្មានជាប់ទោសអ្វីទាំងអស់។

នៅថ្ងៃទី២២ ខែកុម្ភះ ឆ្នាំ២០០៦ Joran ហោះទៅកាន់ទីក្រុង New York នៃសហរដ្ឋអាមេរិក ដើម្បីផ្តល់កិច្ចសម្ភាស៍ទៅកាន់ក្រុមហ៊ុនសារព័ណ៌មាន ABCnews។

ចម្លើយរបស់លោកពេលនោះ ខុសគ្នាជាមួយចម្លើយដែលគេប្រាប់គ្រួសាររបស់ Natalee កាលពីឆ្នាំ២០០៥។ Joranបានឆ្លើយថាយប់នោះ លោកបានជូននាងទៅសមុទ្រក្បែរសណ្ឋាគារដែលនាងស្នាក់នៅ ហើយ Joran

បានបញ្ជាក់ដែរថាទំនាក់ទំនងរបស់ពួកគេនៅយប់នោះឈានទៅដល់ការរួមមេត្រីជាមួយគ្នាផងដែរ ក៏ប៉ុន្តែមិនបានរួមមេត្រីនោះទេ ព្រោះJoranមិនមានចំណង់។

នៅពេលដែលគេសួរថា ពីដំបូងហេតុអ្វីបានជាលោកកុហកគ្រួសារ Natalee? Joran បានឆ្លើយថារូបគេភ័យ ហើយមិនចង់អោយគ្រួសាររបស់គេ និងសង្សារគេដឹងទេ។

ក្រៅពីនឹងលោកក៏បានទុកនាងនៅសមុទ្រម្នាក់ឯង ហើយទូរស័ព្ទអោយ Kalpoe មកយកគេត្រឡប់ទៅផ្ទះវិញ។

និយាយដល់ចំណុចនេះ លោកថាលោកមានកំហុសដែរ ដែលទុកនាងចោលម្នាក់ឯង ប៉ុន្តែធ្វើ៉ម៉េចបើរឿងវាកើតឡើងបាត់ទៅហើយ។ នេះជាលើកចុងក្រោយដែល Joran ឃើញ Natalee។ Joranក៏បានបញ្ជាក់ដែរថាលោកមិនបានសម្លាប់នាងនោះទេ។ ការសម្ភាស៍ក៏បានបញ្ចប់។

ក្រោយពីការបាត់ខ្លួន Natalee អស់រយះពេល ៥ឆ្នាំ រឿងរ៉ាវចម្រូងចម្រាស់ក៏បានមកដល់ ពោលគឺនៅចុងខែមីនា ឆ្នាំ២០១០ Joran បានផ្ញើអ៊ីម៉ែលមួយ ទៅកាន់មេធាវីរបស់គ្រួសារ Natalee គឺ Kelly ថា រូបគេនឹងបង្ហាញប្រាប់ទីតាំងសាកសពរបស់ Natalee បើសិនជាគ្រួសាររបស់នាងព្រមប្រគល់ប្រាក់២៥០០០$ ជាមុន និងត្រូវប្រគល់ប្រាក់225000$បន្ថែមទៀត។ Kelly ក៏យល់ព្រមរួចក៏យកដំណឹងនេះទៅប្រាប់FBI។

នៅថ្ងៃទី១០ ឧសភា ឆ្នាំ២០១០ Kelly និងក្រុមគ្រួសាររបស់Nataleeបានកាន់លុយចំនួន១០០០០$ ទៅជួប Joran នៅឯកោះ Aruba រួច Joranក៏បានប្រាប់ថាសាកសពនាងត្រូវឪពុករបស់គេកប់ក្រោមគ្រឹះសរសេរផ្ទះរបស់គេ។

លុយចំនួន១៥០០០$ទៀតក៏បានផ្ញើទៅកាន់កុងរបស់Joran។ ក្រោយមក Joran បានប្រាប់ថារូបគេកុហក រួចក៏រត់គេចខ្លួនទៅលេងល្បែងនៅឯប្រទេស Peru។

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១០ Joranបានសម្លាប់នារីសញ្ជាតិ Peru ម្នាក់ឈ្មោះថា Stephany Flores ដែលជាអ្នកលេងបុកបីយ៉ែរនៅសណ្ឋាគារមួយ ក្រុង Lima នៃប្រទេស Peru។

Joran សម្លាប់នាងព្រោះនាងមិនស្តាប់តាមបង្គាប់ដែល Joranអោយនាងស្ងាត់។

ព្រៃរឿងសូមបញ្ជាក់ដែរថា Joran និងStephany គ្រាន់តែជាអ្នកស្គាល់គ្នានៅកន្លែងលេងល្បែងតែប៉ុណ្ណោះ ហើយ Joran សម្លាប់នាងដោយប្រើប្រាស់អំហិង្សា វ៉ៃនាងរហូតទាល់តែនាងស្លាប់។

នៅថ្ងៃទី៣ ខែមិថុនា Joranត្រូវបានប៉ូលិសចាប់ខ្លួននៅឯប្រទេស Chile និងបញ្ជូនមកកាន់ប្រទេស Peruវិញ ដើម្បីអោយតុលាការសួរចម្លើយនិងចាត់ការតាមផ្លូវច្បាប់។

ប៉ុន្មានថ្ងៃក្រោយមក Joran ត្រូវបានតុលាការអាមេរិកចោទពីបទចាប់ជំរិត និងកំរាមកំហែងទារប្រាក់ពីក្រុមគ្រួសារ Natalee ចំនួន ២៥០០០០$។

អ្នកទាំងអស់គ្នាប្រាកដជាឆ្ងល់ហើយថាហេតុអ្វីបានជាប៉ូលិសមិនចាប់ខ្លួន Joran មុនពេលដែលគេសម្លាប់ Stephany ព្រោះពេលភ្លាមនោះមិនទាន់មានកុស្តតាងគ្រប់គ្រាន់សំរាប់ចោទទៅលើ Joran។

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២ ថៅក្រុមប្រទេស Peru បានសម្រេចក្តីកាត់ទោសជាប់គុក២៨ឆ្នាំពីបទឃាទកម្មសម្លាប់មនុស្ស មិនតែប៉ុណ្ណោះ Joran ក៏ត្រូវបានតុលាការអាមេរិកកាត់សេចក្តីអោយ Joran សងថ្លៃប្រាក់ជំនឿចិត្តក្រុមគ្រួសារ Natalee ចំនួន ៧៥០០០$ ថែមទៀតផង។

រឯការបាត់ខ្លួនរបស់ Natalee វិញក៏មិនទាន់រកឃើញថា Joran ពាក់ព័ន្ធដែរ។ ហើយមុនថ្ងៃតុលាការកាត់ទោស Joran មួយថ្ងៃ តុលាអាមេរិករដ្ឋAlabamaក៏បានប្រកាសជាផ្លូវការណ៏ថា Natalee ស្លាប់បាត់ហើយ។

ជាចុងក្រោយ អស់រយៈពេល១៦ឆ្នាំហើយ ដែល Natalee បាត់ខ្លួននិងមិនទាន់រកឃើញសូម្បីតែសាកសព។ ទោះបីជាត្រូវតុលាការប្រកាសថាស្លាប់ហើយក៏ដោយ ឪពុកម្តាយរបស់ Natalee គឺ Beth និងDave បែកបាក់គ្នាក៏ពិតមែន ក៏ប៉ុន្តែពួកគេនៅតែស្រលាញ់ Natalee និងរង់ចាំ Natalee ត្រឡប់មកផ្ទះជានិច្ច ព្រោះថាពួកគេមិនទាន់អស់ចិត្តនោះទេ

លុះត្រាតែពេយកគេរកឃើញសាកសពរបស់នាង។ ម្យ៉ាងវិញទៀតគេនៅតែជឿជាក់ថាមានតែJoranទេដែលដឹងច្បាស់រឿងនេះ។

ការបាត់ខ្លួននេះក៏បានធ្វើអោយឪពុកម្តាយរបស់គេក្លាយទៅជាអ្នកស៊ើបអង្កេតផ្ទាល់ទៅលើរឿងក្តីនេះ ហើយថែមទាំងមានថតជាឯកសាខ្សែវីដេអូ នៅលើអ៊ីនធឺណែតទៀតផង។ បើប្រិយមិត្តរបស់ព្រៃរឿងចង់ដឹងលំអិតអាចធ្វើការស្រាវជ្រាវបន្ថែមបាន។

**Ending**

តាមរយះរឿងរ៉ាងខាងលើនេះ យើងអាចស្វែងយល់បានថា កាលដែលយើងទៅកន្លែងណាក៏ដោយ ការប្រុងប្រយ័ត្ន ការចេះសង្កេត ពិចារណាគឺត្រូវតែមានជានិច្ច មិនត្រូវធ្វេសប្រហែសដោយប្រការណាមួយឡើយ ព្រោះក្នុងសង្គមមួយ គឺតែងតែមានមនុស្សល្អ និងអាក្រក់។

យើងនឹងជួបគ្នាម្តងទៀត នៅ CamID Podcast ក្រោយ។

សម្រាប់ពេលនេះ សុបិនល្អ និងរាត្រីសួស្តី។

Links and Resources

https://abcnews.go.com/

https://www.eonline.com/

https://www.oxygen.com/

https://www.biography.com/

https://www.washingtonpost.com/

https://www.vanityfair.com/news/

https://www.crimeandinvestigation.co.uk/

https://abcnews.go.com/

https://www.cbsnews.com/

https://www.cnn.com/